Cranbourne Carlisle Primary School

**Principal:** *Nicky Walker*
**Assistant Principal:** *Anne McDonald*
**Assistant Principal:** *Kerry Bates*
**Assistant Principal:** *Mick Sweeney*
**Business Manager:** *Nicholas Macura*

**19.5.2020**

# CCPS ខូវីឌ-១៩ គោលការណ៍ណែនាំស្តីអំពីការវិលត្រឡប់ទៅសាលារៀនវិញ

## វិធានការសុខភាព និងសុវត្ថិភាពរបស់សាលារៀន

- គណៈកម្មការនាយកការពារសុខភាពអូស្ត្រាលី (AHPPC) បានណែនាំថា ‘បទបញ្ញាទីកន្លែងមានមនុស្សមូលផ្តុំគ្នាច្រើន’ មិនលើសពីមនុស្សម្នាក់ក្នុងទំហំបួនម៉ែត្រការ៉េ គឺមិនសមស្រប ឬអាចអនុវត្តជាក់ស្តែងបានទេនៅក្នុងថ្នាក់រៀន ឬច្រករបៀង ហើយក៏មិនអាចរក្សាគម្លាត១.៥ម៉ែត្រ រវាងសិស្សក្នុងអំឡុងពេលធ្វើសកម្មភាពក្នុងថ្នាក់រៀនដែរ។ ហេតុដូច្នេះហើយ សមាមាត្រដែលបានបង្កើតឡើងពីមុននៃសិស្សចំនួន១០នាក់ក្នុងមួយថ្នាក់ គឺលែងតម្រូវឱ្យមាននៅតាមសាលារៀនទៀតទេ។
- ដើម្បីគាំទ្រដល់បុគ្គលិកសាលាទាំងអស់ត្រៀមបម្រុងសម្រាប់ការផ្លាស់ប្តូរនោះ **ថ្ងៃច័ន្ទ ទី២៥ ខែឧសភា ឆ្នាំ២០២០ គឺជាថ្ងៃដែលសិស្សមិនទៅសាលារៀន** ។ សាលារៀននឹងប្រើថ្ងៃនេះដើម្បីធានាថាដំបូន្មានផ្នែកសុខភាពនឹងត្រូវបានអនុវត្តក្នុងសាលារៀនរបស់ពួកគេ បង្កើតឡើងវិញនូវទម្លាប់សាលារៀន បង្កើតវិធីសាស្ត្រដើម្បីវាយតម្លៃវឌ្ឍនភាពនៃការសិក្សារបស់សិស្សក្នុងអំឡុងពេលនៃការរៀនសូត្រពីចម្ងាយ និងអាចបត់បែនបាន និងកំណត់សិស្សដែលត្រូវការការផ្គត់ផ្គង់ផ្នែកសុខភាព និងសុខុមាលភាពភ្លាមៗ។
- យើងខ្ញុំផ្តល់តម្លៃដល់សារៈសំខាន់នៃការគាំទ្រសិស្សដើម្បីវិលត្រឡប់មករកទម្លាប់ធម្មតាវិញ ការទទួលស្គាល់ពីស្ថានភាព ការផ្តល់ព័ត៌មានសមស្របខាងការអភិវឌ្ឍអំពីអ្វីដែលកំពុងកើតឡើង ក៏ដូចជាការផ្តល់កន្លែងសុវត្ថិភាពដល់សិស្សដើម្បីលើកឡើងពីកង្វល់ និងអារម្មណ៍របស់ពួកគេផងដែរ។

សិស្សទាំងអស់នៅក្នុងកម្រិតថ្នាក់ដែលត្រឡប់ទៅកាន់ការបង្រៀននៅនឹងកន្លែងវិញ ត្រូវបានរំពឹងថានឹងមកសាលារៀន។ សាលារៀនមិនបានរំពឹងថានឹងផ្តល់ការរៀនសូត្រពីចម្ងាយដែលឪពុកម្តាយជ្រើសរើសដើម្បីរក្សាសិស្សទាំងនេះនៅផ្ទះទេ លើកលែងតែពេលណាការនេះផ្អែកលើដំបូន្មានខាងវេជ្ជសាស្ត្រ។ សូមទាក់ទងមកជំនួយការនាយកអនុសាលារបស់អ្នក ប្រសិនបើមានករណីបែបនេះ។

| | |
|---|---|
| មត្តេយ្យសាលា - ថ្នាក់ទី២៖ | Anne McDonald |
| ថ្នាក់ទី៣ ដល់ថ្នាក់ទី៦៖ | Kerry Bates |
| សុខុមាលភាព៖ | Kerry Bates |

## វិធានការសុខភាព និងសុវត្ថិភាពផ្សេងទៀត

- ឧបករណ៍សួនកុមារអាចប្រើប្រាស់បាន។ ទោះជាយ៉ាងណាក៏ដោយ សិស្សនឹងត្រូវអនុវត្តអនាម័យលាងដៃមុន និងក្រោយពេលប្រើប្រាស់។ សួនកុមារនឹងត្រូវបានលាងសម្អាតក្រោយម៉ោងឈប់សម្រាក និងពេលអាហារថ្ងៃត្រង់ជាមួយថ្នាំសម្លាប់មេរោគប្រើនៅតាមមន្ទីរពេទ្យ ដែលជាផ្នែកនៃកម្មវិធីសម្អាតដែលបានធ្វើឱ្យប្រសើរឡើង។
- ប្រសិនបើប្រើប្រាស់ឧបករណ៍ចែករំលែក អនាម័យលាងដៃយ៉ាងតឹងរ៉ឹងមុន និងក្រោយពេលប្រើប្រាស់នឹងត្រូវបានអនុវត្ត។
- សិស្សនឹងចាំបាច់ត្រូវយកដបទឹកផ្ទាល់ខ្លួនសម្រាប់ប្រើប្រាស់នៅសាលារៀន ដោយព្រោះថាសិស្សនឹងមិនអាចផឹកទឹកដោយផ្ទាល់ចេញពីកន្លែងទឹកបាញ់សម្រាប់ផឹកបានទេ។



*15 Silky Oak Drive*
*Cranbourne, 3977*
*Phone: 5991 3600*
Email: cranbourne.carlisle.ps@edumail.vic.gov.au
Website: http://www.cranbournecarlisleps.vic.edu.au

*“Many Cultures One Community”*

- *គោលការណ៍សិស្សប្រើប្រាស់ទូរស័ព្ទចល័ត* របស់ DET នៅតែអនុវត្តជាដដែល។ សិស្សនឹងត្រូវបានប្រាប់ឱ្យសម្អាតទូរស័ព្ទរបស់ពួកគេជាមួយក្រដាសជូតសម្លាប់មេរោគ នៅពេលប្រគល់ឱ្យការិយាល័យរៀងរាល់ព្រឹក។ សិស្សអាចរក្សាទូរស័ព្ទឱ្យនៅបើកជាមួយកម្មវិធី COVID SAFE app ដោយដាក់វាឱ្យដំណើរការភ្លាមៗមុន និងក្រោយម៉ោងសាលា។ សាលារៀនស្ថិតនៅក្នុងបរិស្ថានដែលត្រូវបានគ្រប់គ្រង រួមមានកំណត់ត្រានៃសិស្ស បុគ្គលិក និងភ្ញៀវដែលមកសាលារៀន ដែលអាចគាំទ្រការតាមដានអំពីការប៉ះពាល់។

## សុខភាព និងសុខុមាលភាពផ្លូវចិត្ត

ប្រសិនបើអ្នកមានការព្រួយបារម្ភជាពិសេសអំពីសុខភាព និងសុខុមាលភាពផ្លូវចិត្តរបស់កូនអ្នក សូមជូនដំណឹងដល់ជំនួយការនាយកឱ្យបានឆាប់ ដើម្បីធានាថាយើងខ្ញុំអាចទទួលបានសេវាកម្ម និងការគាំទ្រណាមួយដែលអាចមានផ្តល់។

| | |
|---|---|
| មត្តេយ្យសាលា - ថ្នាក់ទី២៖ | Anne McDonald |
| ថ្នាក់ទី៣ ដល់ថ្នាក់ទី៦៖ | Mick Sweeney |
| សុខុមាលភាព៖ | Kerry Bates |

## ការសម្អាត

ការរៀបចំសម្អាតដែលបានពង្រីក និងបង្កើនឡើងត្រូវបានណែនាំ ហើយនឹងបន្ត។ នេះពាក់ព័ន្ធនឹងការសម្អាតពេញទូទាំងថ្ងៃ ដើម្បីធានាថាហានិភ័យនៃការចម្លងរោគត្រូវបានកាត់បន្ថយសម្រាប់ផ្ទៃដែលប៉ះពាល់ច្រើន។

## ការមកសាលារៀននៅនឹងកន្លែង

សកម្មភាពសំខាន់បំផុតមួយដែលសហគមន៍សាលារៀនអាចអនុវត្តដើម្បីកាត់បន្ថយហានិភ័យនៃការចម្លងមេរោគវីរុសកូរ៉ូណា (ខូវីឌ-១៩) គឺដើម្បីធានាថាបុគ្គលិក កុមារ និងមនុស្សវ័យក្មេងដែលមិនមានសុខភាពល្អ ត្រូវតែស្នាក់នៅផ្ទះ។

ខណៈពេលដែលហានិភ័យនៃការចម្លងវីរុសមានកម្រិតទាប បុគ្គលិក ឬសិស្សដែលមានហានិភ័យខ្ពស់នៃជំងឺធ្ងន់ធ្ងរ គួរតែវាយតម្លៃជាលក្ខណៈបុគ្គលសម្រាប់ភាពសមស្របនៃការមកសាលារៀននៅនឹងកន្លែងនៅពេលនេះ ដោយមានការគាំទ្រពីគ្រូពេទ្យជំនាញរបស់ពួកគេ។

ដោយសារហានិភ័យចម្បងនៃការចម្លងវីរុសកូរ៉ូណា (ខូវីឌ-១៩) ក្នុងបរិស្ថានសាលាគឺរវាងមនុស្សធំ ដូច្នេះភ្ញៀវមកបរិវេណសាលានឹងត្រូវបានកំណត់ចំពោះអស់អ្នកដែលផ្តល់ ឬគាំទ្រសេវាកម្ម និងប្រតិបត្តិការដែលសំខាន់ចាំបាច់របស់សាលារៀនប៉ុណ្ណោះ។ ប្រសិនបើឪពុកម្តាយចាំបាច់ត្រូវទាក់ទងមកសាលារៀនដោយហេតុផលណាមួយ សូមទូរស័ព្ទទៅការិយាល័យសាលា។

### បុគ្គលិក និងសិស្សដែលមិនស្រួលខ្លួនទាំងអស់ ត្រូវតែស្នាក់នៅផ្ទះ។

ឪពុកម្តាយ / អ្នកថែទាំសិស្សដែលមានតម្រូវការផ្នែកវេជ្ជសាស្ត្រស្មុគស្មាញ (រួមទាំងអ្នកដែលមានប្រព័ន្ធភាពស៊ាំនឹងជំងឺចុះខ្សោយ) គួរតែស្វែងរកដំបូន្មានពីអ្នកអនុវត្តខាងវេជ្ជសាស្ត្ររបស់សិស្ស ដើម្បីគាំទ្រដល់ការសម្រេចចិត្តថាតើការអប់រំនៅនឹងកន្លែងមានលក្ខណៈសមរម្យឬក៏អត់ ដោយកត់សម្គាល់ថាដំបូន្មាននេះអាចផ្លាស់ប្តូរ អាស្រ័យលើស្ថានភាពនៃការឆ្លងរាលដាលនៃវីរុសកូរ៉ូណា (ខូវីឌ-១៩) នៅក្នុងរដ្ឋវិចថូរៀ។ នេះស្របតាមគោលការណ៍តម្រូវការផ្នែកថែទាំសុខភាពរបស់ DET ។ សាលារៀននឹងផ្គត់ផ្គង់គ្រូសារណាមួយដែលមានតម្រូវការបន្ថែមក្នុងផ្នែកនេះ។

សន្និបាតសាលា ដំណើរកម្សាន្តសាលា ការបោះជំរុំ និងការជួបជុំធំៗមិនចាំបាច់ផ្សេងទៀតត្រូវបានពន្យារពេល រហូតដល់មានការជូនដំណឹងបន្ថែម។



*15 Silky Oak Drive*
*Cranbourne, 3977*
*Phone: 5991 3600*
Email: cranbourne.carlisle.ps@edumail.vic.gov.au
Website: http://www.cranbournecarlisleps.vic.edu.au

Principal: *Nicky Walker*
Assistant Principal: *Anne McDonald*
Assistant Principal: *Kerry Bates*
Assistant Principal: *Mick Sweeney*
Business Manager: *Nicholas Macura*

## អនាម័យ

មនុស្សគ្រប់រូបអាចការពារខ្លួនពួកគេ និងការពារការឆ្លងរាលដាលនៃវីរុសកូរ៉ូណា (កូវីឌ-១៩) ដោយបន្តអនាម័យលាងដៃប្រកបដោយប្រសិទ្ធភាព។ វិធានការអនាម័យដែលបានធ្វើឱ្យប្រសើរឡើង នឹងបន្តក្នុងអំឡុងពេលត្រឡប់មកការបង្រៀន និងការរៀនសូត្រនៅនឹងកន្លែងវិញ។

- បុគ្គលិក និងសិស្សទាំងអស់នឹងត្រូវអនុវត្តអនាម័យលាងដៃឱ្យបានទៀងទាត់ ជាពិសេសនៅពេលមកដល់សាលារៀន មុន និងក្រោយពេលបរិភោគ បន្ទាប់ពីញើសច្រមុះ ក្អក កណ្តាស់ ឬប្រើប្រាស់បង្គន់។ ការនេះនឹងត្រូវបានណែនាំ ឬត្រួតពិនិត្យដោយបុគ្គលិក ពេលណាមានតម្រូវការ។
- កន្លែងណាដែលមិនមានសាប៊ូ និងទឹកអាចប្រើបានងាយស្រួល ទឹកថ្នាំអនាម័យលាងដៃនឹងមានផ្តល់ជូននៅគ្រប់បន្ទប់។
- សិស្សនឹងមិនបានអនុញ្ញាតឱ្យផឹកដោយផ្ទាល់ពីកន្លែងទឹកបាញ់សម្រាប់ផឹកទេនៅពេលនេះ។ ជាជំនួសវិញនោះ ពួកគេគួរតែយកដបទឹកផ្ទាល់ខ្លួនសម្រាប់ប្រើប្រាស់ (និងចាក់ទឹកបំពេញ) នៅសាលារៀន។

## ការមកដល់សាលារៀន និងការចេញពីសាលារៀន

ដោយសារហានិភ័យចម្លងនៃការចម្លងវីរុសកូរ៉ូណា (កូវីឌ-១៩) មកបរិស្ថានសាលារៀនគឺមកពីមនុស្សពេញវ័យ ដូច្នេះការនៅជិតៗគ្នារវាងសមាជិកពេញវ័យនៃសហគមន៍សាលាគួរតែបានជៀសវាង ជាពិសេសនៅអំឡុងពេលយកកូនមកសាលា និងយកកូនពីសាលា។

- បុគ្គលិក និងឪពុកម្តាយត្រូវបានតម្រូវឱ្យគោរពវិធានការរក្សាគម្លាតផ្នែករាងកាយ ដោយមិនត្រូវប្រជុំគ្នានៅតាមតំបន់ខាងក្នុង ឬជុំវិញសាលារៀនឡើយ។
- ការរៀបចំដើម្បីអនុវត្តការរក្សាគម្លាតផ្នែករាងកាយ និងកាត់បន្ថយការធ្វើអន្តរកម្មរវាងសិស្ស និងមនុស្សពេញវ័យនៅក្នុងសាលារៀន និងនៅតាមចំណុចចូលសាលារៀន រួមមាន៖
    - ការដាក់ស្លាកចំណុចនៅតាមច្រកទ្វារសាលារៀន ដើម្បីលើកទឹកចិត្តឱ្យមានគម្លាតរវាងមនុស្សធំ
    - ឪពុកម្តាយមិនបានអនុញ្ញាតឱ្យនៅនឹងកន្លែងទេ ហើយត្រូវបានស្នើសុំឱ្យទាក់ទងមកសាលារៀនតាមរយៈទូរស័ព្ទ ឬអ៊ីម៉េលពេលណាចាំបាច់
    - ការប្រជុំសំខាន់ៗនឹងត្រូវធ្វើឡើងតាមរយៈការធ្វើសន្និសីទតាមវីដេអូ
    - ដើម្បីគោរពគោលការណ៍ណែនាំការរក្សាគម្លាតនៅក្នុងសង្គម អន្តរកម្ម និងការរាក់ទាក់ណាមួយ ត្រូវតែបានធ្វើឡើងដោយមិនប៉ះពាល់គ្នា
    - ពេលវេលាសម្រាប់ការយកកូនមកសាលា និងការយកកូនពីសាលាដែលមានលក្ខណៈតៗគ្នាអាចធ្វើទៅបាន ដើម្បីកាត់បន្ថយចំនួនមនុស្សពេញវ័យដែលមកប្រជុំគ្នានៅតាមច្រកទ្វារសាលារៀន ឬនៅខាងក្រៅថ្នាក់រៀន ប្រសិនបើត្រូវ។



*15 Silky Oak Drive*
*Cranbourne, 3977*
*Phone: 5991 3600*
Email: cranbourne.carlisle.ps@edumail.vic.gov.au
Website: http://www.cranbournecarlisleps.vic.edu.au

*"Many Cultures One Community"*